Department of Developmental Services

# (ក្រសួងបម្រើសេវាកម្មជនវិកលចរិក)

# ដំណើរការដាក់ពាក្យបណ្ដឹងបកអាក្រាតចំពោះមជ្ឈមណ្ឌលប្រចាំតំបន់ ឬអ្នកផ្ដល់សេវាកម្ម/អ្នកមការ ព័ត៌មានសម្រាប់ដាក់ពាក្យប្ដឹង និងទំនាក់ទំនង

<u>និយមន័យអំពីពាក្យបណ្ដឹងបកអាក្រាតចំពោះមជ្ឈមណ្ឌលប្រចាំតំបន់ (Regional Center) ឬ អ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ ៖</u>

ការប្ដឹងបកអាក្រាតចំពោះមជ្ឈមណ្ឌលប្រចាំតំបន់ ឬអ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ មានន័យថា ការរាយការណ៍អំពី "សកម្មភាពដែលមិនសមរម្យរបស់មជ្ឈមណ្ឌលប្រចាំតំបន់ ឬអ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ" ។

- "សកម្មភាពមិនសមរម្យរបស់មជ្ឈមណ្ឌលប្រចាំតំបន់" មានន័យថាគឺជាសកម្មភាព របស់មជ្ឈមណ្ឌលប្រចាំតំបន់ ឬនិយោជិក មន្ត្រី ឬសមាជិកគណៈគ្រប់គ្រងរបស់មជ្ឈមណ្ឌលប្រចាំតំបន់ ដែលបានប្រព្រឹត្តក្នុងការបំពេញការងារសម្រាប់មជ្ឈមណ្ឌល ដោយមានការរំលោភចំពោះច្បាប់ ឬបទបញ្ញត្តិរបស់សហព័ន្ធ ឬរបស់រដ្ឋ ការប្រព្រឹត្តិ រំលោភចំពោះលក្ខខណ្ឌនៃកិច្ចសន្យា ការបន្លំ ឬកេងពន្ធអាករ ការប្រើទ្រព្យសម្បត្តិរបស់ រដ្ឋក្នុងផ្លូវខុស ឬការប្រព្រឹត្តិខុសធ្ងន់ធ្ងរ អសមត្ថភាព ឬការបំពេញការងារគ្មានប្រសិទ្ធិភាព ។

- "សកម្មភាពមិនសមរម្យរបស់អ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ" មានន័យថាគឺជាសកម្មភាព របស់អ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ ឬនិយោជិក មន្ត្រី ឬសមាជិកគណៈគ្រប់គ្រង របស់អ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ ក្នុងផ្ដល់សេវាកម្មដែលបានទទួលថវិកាទំនុកបំរុងពី DDS ដោយការប្រព្រឹត្តិរំលោភលើលក្ខខណ្ឌនៃកិច្ចសន្យា ការបន្លំ ឬកេងពន្ធអាករ ការប្រើទ្រព្យសម្បត្តិរបស់រដ្ឋាភិបាលក្នុងផ្លូវខុស ឬការប្រព្រឹត្តិខុសធ្ងន់ធ្ងរ អសមត្ថភាព ឬការបំពេញការងារគ្មានប្រសិទ្ធិភាព ។

ក្រសួងបំរើសេវាកម្មជនវិកលចរិក (Department of Developmental Services-DDS) បានរៀប ចំឲ្យមានដំណើរការផ្សេងៗគ្នាលើការប្ដឹង និងការធ្វើឧទ្ធរណ៍ចំពោះអ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ ភ្នាក់ងារ មន្ទីរ មាតាបិតា និងអ្នកទទួលផល ។ ដំណើរការទាំងនេះគឺរួមទាំងបណ្ដឹងចំពោះសិទ្ធិអ្នកទទួលផល (Consumer Rights Complaints) បណ្ដឹងចំពោះសេវាកម្មថែទាំកុមារក្នុងបឋមវ័យ (Early Start Complaints)

សំណើសុំការអនុវត្តន៍ច្បាប់ឲ្យមានភាពយុត្តិធម៌ (Due Process Requests) និងសំណើធ្វើសន្និសិទសន្ធានកម្ម (Mediation Conference Requests) សំណើសុំសវនាការយុត្តិធម៌នៃច្បាប់សិទ្ធិជនពិការរដ្ឋកាលីហ្វ័រនីញ៉ា (Lanterman Act Fair Hearing Requests) បណ្ដឹងច្បាប់ថៃថល 17 (Title 17 Complaints) បណ្ដឹង និងមតិយោបល់របស់ពលរដ្ឋ (Citizen Complaints and Comments) (សម្រាប់បញ្ជីប្រធានបទសូមទស្សនាគេហទំព័រ http://www.dds.ca.gov/Complaints/Home.cfm) ។ ដំណើរការបណ្ដឹង និងឧទ្ធរណ៍ ទាំងអស់នេះ មានទម្រង់ការដាច់ដោយឡែក និងខុសៗគ្នា សម្រាប់ដំណោះស្រាយ ។ ដំណើរការនៃសេចក្ដីបង្គាប់នេះ ពាក់ព័ន្ធតែជាមួយនឹងបណ្ដឹងបកអាក្រាតចំពោះមជ្ឈមណ្ឌលប្រចាំតំបន់ ឬអ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ ដូចអ្វីដែលមានរៀបរាប់ជូនពីខាងលើ ។

<u>ការសម្ងាត់</u>

ក្រសួងបម្រើសេវាកម្មជនវិកលចរិក (DDS) នឹងចាត់គ្រប់វិធានការទាំងអស់ ដើម្បីធានា តាមអ្វីដែលខ្លួនអាចធ្វើបាន ក្នុងការរក្សាការសម្ងាត់ ចំពោះអ្នកដាក់ពាក្យបណ្ដឹង ដើម្បីប្ដឹង បកអាក្រាតអ្នកទាំងនោះ ប្រសិនបើអ្នកប្ដឹងសុំឲ្យរក្សាការសម្ងាត់នោះ ។ក៏ប៉ុន្តែ មានករណីដ៏ កម្រមួយចំនួនបានកើតឡើង ដែលធ្វើឲ្យ DDS មិនអាចមានលទ្ធភាព រក្សាជូនបាននូវការសម្ងាត់ ដោយសារការទទួលខុសត្រូវជាអាជ្ញាយុកាលរបស់ខ្លួន (រួមទាំងការធានាចំពោះសុខភាព និងសុវត្ថិភាពរបស់អ្នកទទួលផល និងការអនុវត្តតាមកិច្ចសន្យារបស់ មជ្ឈមណ្ឌលប្រចាំតំបន់) ក្រសួងនឹងព្យាយាមជូនដំណឹងដល់អ្នកដាក់ពាក្យប្ដឹង អំពីសេចក្ដីត្រូវ ការរបស់ខ្លួនក្នុងការលាតត្រដាង នូវព័ត៌មានជាក់លាក់ណាមួយ នៅមុនការបញ្ចេញនូវព័ត៌មានអត្តសញ្ញាណកម្ម ។ លើសពីនេះទៅទៀត អត្តសញ្ញាណកម្មរបស់អ្នកប្ដឹង អាចត្រូវបញ្ជូនទៅឲ្យភ្នាក់ងារអនុវត្តច្បាប់ដែលពាក់ព័ន្ធ ដែលពួកគេជាអ្នកធ្វើការស៊ើបអង្កេតបទឧក្រិដ្ឋកម្ម ។

<u>អំពីការដាក់ពាក្យបណ្ដឹង</u>

យើងខ្ញុំត្រូវការនូវសំណេរដែលមានន័យច្បាស់លាស់ និងជាក់លាក់ រៀបរាប់អំពីសកម្មភាព ដែលប្រព្រឹត្តិឡើងដោយមិនសមរម្យ រួមទាំងភស្តុតាងណាមួយដែលអ្នកមាន សម្រាប់គាំទ្រ លើការចោទប្រកាន់របស់អ្នក ។

ប្រសិនបើអ្នកមិនផ្ដល់ជូននូវឈ្មោះ ឬព័ត៌មានដទៃទៀត (សាក្សី ឬឯកសារភស្តុតាង) ដែលអាច បញ្ជាក់ជូនយ៉ាងច្បាស់ចំពោះបុគ្គល ដែលអ្នកចោទប្រកាន់ពីការប្រព្រឹត្តិមិនសមរម្យ ព្រមទាំងឈ្មោះមជ្ឈមណ្ឌលប្រចាំតំបន់ ឬអ្នកផ្ដល់សេវាកម្ម/អ្នកម៉ៅការ ដែលបុគ្គលនោះបម្រើការទេនោះ វាអាចធ្វើឲ្យយើងខ្ញុំមិនមានព័ត៌មានគ្រប់គ្រាន់ សម្រាប់បើកការស៊ើបអង្កេត ឡើយ ។ ឯកសារដែលដាក់ជូនជាភស្តុតាង គួរដាក់តែសំណៅថតចម្លង អ្នកត្រូវរក្សាទុកសំណៅដើម ដោយសារថាពេលដែលអ្នកដាក់មកហើយ អ្នកមិនអាចយកវាទៅវិញបានឡើយ ។

បើទោះបីជាពាក្យបណ្តឹងអាចត្រូវដាក់ប្តឹងជាអនាមិកភាពក៏ដោយ ប្រសិនបើអ្នកមិនផ្តល់ជូន នូវព័ត៌មានឲ្យបានគ្រប់គ្រាន់ ហើយយើងខ្ញុំមិនមានមធ្យោបាយណាសម្រាប់ទំនាក់ទំនងជាមួយអ្នកទេនោះ យើងខ្ញុំប្រហែលជាមិនអាចធ្វើការស៊ើបអង្កេតចំពោះ ការចោទប្រកាន់ដែល អ្នកបានធ្វើឡើងឡើយ ។

**<u>របៀបដាក់ពាក្យបណ្តឹង ៖</u>**

អ្នកអាចដាក់ពាក្យបណ្តឹង ដោយការទំនាក់ទំនងជាមួយនឹង ៖

- ផ្នែកប្រតិបត្តិការសហគមន៍ (Community Operations Division)

  (916) 654-1958

  (916) 654-1987 ទូរសារ

  1600 9th Street, Room 320, MS 3-9

  Sacramento, CA 95814

- ផ្នែកផ្តល់សេវាកម្ម និងគាំទ្រសហគមន៍ (Community Services and Supports Division) (សម្រាប់បណ្តឹងអំពីសេវាកម្មមើលថែទាំកុមារក្នុងវ័យបឋម-Early Start program services)

  (916) 654-2716

  (916) 654-3020 ទូរសារ

  1600 9th Street, Room 340, MS 3-24

  Sacramento, CA 95814